## ឧបសម្ព័ន្ធ៣-២

## ឯកសារលិខិតបទដ្ឋាន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**Kingdom of Cambodia**

Nation Religion King

**ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**

Ministry of Industry, Mines and Energy

№ ៧៦៧២ ឧរថ.ធរ.អប.

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ៥ ឆ្នាំ ២០០៧

## អាជ្ញាប័ណ្ណស្វែងរុករក

---

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៥ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការគ្រប់គ្រង និង ការធ្វើអាជីវកម្មធនធានរ៉ែ ។
- បានឃើញអនុក្រឹត្យលេខ:៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំ និង ប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញកិច្ចព្រមព្រៀងស្ដីពីការសិក្សាស្រាវជ្រាវរ៉ែ Ilmenite នៅតំបន់អូរតាគុត ស្រុកថ្មបាំង ខេត្តកោះកុង ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៥ រវាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រុមហ៊ុន Samnang Rea Thbong Thmor Co.,Ltd ។
- បានឃើញអាជ្ញាប័ណ្ណស្វែងរុករក លេខ:៨៨៩ ឧរថ.ធរ.អប ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៥ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញលិខិតស្នើសុំ ចុះថ្ងៃទី២៨ខែកញ្ញា ឆ្នាំ២០០៧ របស់ក្រុមហ៊ុន Samnang Rea Thbong Thmor Co.,Ltd ។

## <u>សំរេច</u>

**<u>ប្រការ១:</u>** អនុញ្ញាតអោយក្រុមហ៊ុន Samnang Rea Thbong Thmor Co.,Ltd មានអាសយដ្ឋានផ្ទះ លេខ១៣ ផ្លូវលេខ ៥៥៦ សង្កាត់បឹងកក់ ខ័ណ្ឌទួលគោករាជធានីភ្នំពេញ ធ្វើការសិក្សាស្រាវជ្រាវរ៉ែ Ilmenite នៅតំបន់អូរតាគុត

G samnang rea 07

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ១៤១ ទូរសារ: (៨៥៥)២៣ ៤២៨ ២៦៣
45 Preah Norodom Boulivard. Khan Daun Penh. Phone: (855) 23 211 141 Fax: (855) 23 428 263

ស្រុកថ្មបាំង ខេត្តកោះកុង លើផ្ទៃដីទំហំ១២០ គីឡូម៉ែត្រក្រឡា ដែលមានកូអ័រដោណេដូចតទៅ ៖

| ចំណុច | អាប់ស៊ីស | អ័រដោនេ | ចំណុច | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|
| A | 350[000] | 1276[000] | C | 360[000] | 1264[000] |
| B | 360[000] | 1276[000] | D | 350[000] | 1264[000] |

<u>ប្រការ២:</u> ក្រុមហ៊ុន Samnang Rea Thbong Thmor Co.,Ltd ត្រូវដំណើរការសិក្សាស្រាវជ្រាវរ៉ែលើផ្ទៃដី ដែលបានកំណត់ខាងលើ ដោយអនុវត្តទៅតាមផែនការឆ្នាំ និង កម្មវិធីការងាររបស់ខ្លួនដោយធានាអនុវត្តតាមបទដ្ឋានបច្ចេកទេសក្នុងការសិក្សាស្រាវជ្រាវរុករករ៉ែ ។

<u>ប្រការ៣:</u> អាជ្ញាប័ណ្ណនេះមានសុពលភាពរហូតដល់ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៩។ ក្នុងករណីដែលក្រុមហ៊ុននៅតែមិនអាចសិក្សា និង វាយតម្លៃប្រសិទ្ធភាពសេដ្ឋកិច្ចនៃជីករ៉ែនៅតំបន់សម្បទានរបស់ខ្លួន ដើម្បីឈានទៅធ្វើអាជីវកម្មបានទេ ក្រសួងនឹងបញ្ចប់កិច្ចព្រមព្រៀងស្តីពីការសិក្សាស្រាវជ្រាវរ៉ែ Ilmenite នៅតំបន់ខាងលើ ។

<u>ប្រការ៤:</u> ក្នុងករណីប្រព្រឹត្តល្មើសលើលក្ខខណ្ឌ នៃកិច្ចព្រមព្រៀង ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៥ អាជ្ញាប័ណ្ណនេះនឹងត្រូវដកហូត ឬ ត្រូវពិន័យទៅតាមច្បាប់ស្តីពីការគ្រប់គ្រង និង ការធ្វើអាជីវកម្មធនធានរ៉ែ ។

<u>ប្រការ៥:</u> អគ្គនាយក នៃអគ្គនាយកដ្ឋានធនធានរ៉ែ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពលខេត្តកោះកុង និង ប្រធានក្រុមហ៊ុន Samnang Rea Thbong Thmor Co., Ltd ត្រូវទទួលអនុវត្តអាជ្ញាប័ណ្ណនេះតាមភារៈកិច្ច រៀងៗខ្លួន។

<u>ប្រការ៦:</u> អាជ្ញាប័ណ្ណនេះមានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

<u>ចំលងជូន</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងបរិស្ថាន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ
- សាលាខេត្តកោះកុង
- សាលាស្រុកថ្មបាំង
- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

G samnang rea 07